ស-សបាសាក់ SA SA BASSAC

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

+855 (0)17 774 864
www.sasabassac.com

យើងខ្ញុំមានក្ដីសោមនស្សសូមប្រកាសពីការតាំងពិព័រណ៍ និងកម្មវិធីផ្សេងៗរបស់*គម្រោងបណ្ណសារសិល្បៈសិង្ហបុរីនៅ ស-សបាសាក់៖ កូ ហ្វង ហាវ និង ស៊ូ ទិត្យ ស៊ីង* ជាមួយនឹងអ្នករៀបចំពិព័រណ៍ វេរ៉ា ម៉ៃ និង ម៉េឡានី មឺម៉ត ដែលកំណត់យកប្រទេសកម្ពុជា និងការរក្សាបណ្ណសារសិល្បៈរបស់ ស៊ូ ទិត្យ ស៊ីង (១៩១៤ ដល់ ១៩៩៧) នៃ ក្រុមសិល្បៈបុរសដប់នាក់ (Ten Men Art Group) ជាចំនុចស្នូល ដើម្បីបកស្រាយពីភាពពហុទិស របស់ចលនាសិល្បៈសម័យទំនើបនៅក្នុងតំបន់ដែលយើងហៅថាតំបន់អាស៊ីអាគ្នេយ៍។

សិល្បករ កូ ហ្វង ហាវ គឺជាអ្នកទិវានុព្រឹត្តិសិល្បៈសហសម័យដែលនាំមុខគេមួយរូបនៅសិង្ហបុរី ហើយគាត់ក៏បានផ្ដួចផ្ដើម*គម្រោងបណ្ណសារសិល្បៈសិង្ហបុរី (SAPP)* នៅឆ្នាំ២០០៥។ គម្រោង *SAPP* មានផ្ទុករូបថតមានតម្លៃដែលលោក កូ បានថតដោយខ្លួនឯង មានវីដេអូ និងខ្សែសម្លេងកត់ត្រាការសម្ដែង នឹងកិច្ចសន្ទនា ក៏ដូចជាមានស្លាយ ក្រដាសឃោសនា កាតាឡុក ដែលភាគច្រើនទាក់ទងនឹងភូមិសិល្បករ (The Artists Village) ដែលជាសហករណ៍សិល្បៈសហសម័យ មួយ ដែលត្រូវបានគេបង្កើតឡើងនៅឆ្នាំ ១៩៨៨ ដោយសិល្បករ តាំង តាអ៊ូ។ លោក កូ ក៏ជាសមាជិកនៃសហករណ៍ នេះផងដែរ។ ធនធានច្រើនប្រភេទរបស់លោក កូ ទាំងអស់នេះមាននៅពីសម័យកាល ១៩២០ ដល់បច្ចុប្បន្ន។

នៅស-សបាសាក់ លោក កូ នឹងបកស្រាយពីកន្លែងប្រឈមគ្នានៃ *SAPP* នៅចន្លោះឆ្នាំ ១៩៦៣ និង ១៩៨០ ដែលផ្ដោត សំខាន់ទៅលើការងាររបស់ សិល្បករ ស៊ូ ទិត្យ ស៊ីង។ លោក ស៊ូ គឺជាផ្នែកមួយនៃក្រុមសិល្បករបុរស ដប់នាក់ ដែលជាក្រុម សិល្បករអ្នកនិរប្រវេសន្តពីប្រទេសចិន មកកាន់ម៉ាឡាយ៉ា ហើយទើបមកដល់សិង្ហបុរី។ ពួកគាត់មានភាពសកម្មពីឆ្នាំ ១៩៦១ ដល់ឆ្នាំ ១៩៧០ ក្នុងការតាមរកគំនិតបំផុសដើម្បីសម្របខ្លួន ទៅនឹងសោភ័ណភាពរបស់តំបន់អាស៊ីអាគ្នេយ៍។ ការខិតខំប្រឹងប្រែងរបស់ពួកគាត់ និងរចនាបទរូបថតរបស់គាត់បានលាយបញ្ចូលគ្នាជាមួយនឹងព្រឹត្តិការណ៍ដែលបាននឹងកំពុង កើតឡើងអស់រយៈពេល ៣០ ឆ្នាំមុននេះជាមួយនឹង សាលាសិល្បៈណាន់យ៉ាង។ ក្រោយមក រចនាបថនេះត្រូវបានហៅថា «រចនាបទណាន់យ៉ាង»។

ខណៈពេលក្រុមសិល្បៈបុរសដប់នាក់មានភាពឯករាជ្យពីសាលានោះ ជាគោលការណ៍ពួកគេចែករំលែកគំនិតបូព៌ាប្រទេស ឬគំនិតសម្របខ្លួននឹងឋានសួគ៌ត្រូពិចខាងត្បូងមានវប្បធម៌ចម្រុះគ្នាដែលពួកគេគិតថា ជាទីដើមផ្ដល់គំនិតបំផុសដល់ ពួកគេ។ ក្រុមសិល្បករបុរសដប់នាក់ធ្វើដំណើរជាមួយគ្នាផ្ដួចផ្ដើមការតាំងពិព័រណ៍ និងមានរៀបចំអង្គប្រជុំថ្ងៃអាទិត្យដើម្បី ពិភាក្សា និងលើកទឹកចិត្តការអនុវត្តន៍សិល្បៈ។ ពួកគេបានធ្វើដំណើរទៅ ប្រទេសឥណ្ឌូនេស៊ី បនេអូ ថៃ កម្ពុជា និងឥណ្ឌា ផងដែរ។ ដំណើរទស្សនកិច្ចទៅកាន់ ស៊ូម៉ាត្រា នៅឆ្នាំ១៩៧០ គឺជាដំណើរផ្លូវការចុងក្រោយរបស់ពួកគាត់ មុនពេលពួកគាត់បង្កើតខ្លួនជាសមាគមសិល្បៈអាស៊ីអាគ្នេយ៍។ យើងអាចឃើញឥទ្ធពលរបស់ការចុះទស្សនកិច្ចក្រុមនេះ ដោយសារការផ្លាស់ប្ដូរការអនុវត្តន៍សិល្បៈ។ ហើយពួកគាត់ក៏មានឈ្មោះល្បីរន្ទឺខ្លាំងទៅៗ អាស្រ័យគំនូររៀបរាប់ពីជីវិតអ្នកភូមិ នៅក្នុងក្រុមសិក្សា Beaux-Arts (តាមរយៈប្រទេសចិន) និងតាមរយៈបរិបទ និងឥទ្ធិពលនៃទំនាក់ទំនងរបស់ពួកគេ ទៅនឹងទីតាំង។ ទស្សនកិច្ចមក ប្រទេសកម្ពុជា និងប្រាសាទផ្សេងៗ នៅក្នុងឧទ្យានអង្គរ ជាពិសេសគឺចម្លាក់ក្រឡោតនៅ ប្រាសាទបាយ័នបាន ជះឥទ្ធិពលខ្លាំងទៅលើ លោក ស៊ូ ទិត្យ ស៊ីង។ គំនិតគាត់ត្រូវបានផុសឡើងបានតាមគំនិតសមកាល ពីរូបចម្លាក់ ក្រឡោតទាំងនោះ ហើយរូបគំនូរឯកទស្សនីយភាព របស់គាត់បានប្ដូរទៅជារូបពហុទស្សនីយភាពទៅវិញ។ រូបចម្លាក់របស់គាត់ ដែលធ្វើឡើងពីឈើម៉ៃសាក់ បានលើកតម្កើងប្រជាពលរដ្ឋធម្មតាឲ្យក្លាយទៅជាវីរៈជនសម័យថ្មីប្រចាំតំបន់។

ស្នាដៃដែលនឹងតាំងនៅស-សបាសាក់ គឺជាការរួមបញ្ចូលស្នាដៃដើម និងស្នាដៃធ្វើឡើងវិញតាមរយៈទស្សនកិច្ចរបស់ លោក ស៊ូ ទិត្យ ស៊ីង នៅប្រទេសកម្ពុជានៅឆ្នាំ ១៩៦៣ និងគំនិតដែលផុសចេញពីប្រទេសនេះដល់ឆ្នាំ១៩៨០។ ផ្គួបជាមួយគ្នានេះ ដែរ ក៏មានការតាំងពិព័រណ៍ឯកសារផ្សេងៗដែលត្រូវបានជ្រើសរើសពីឯកសារជាច្រើនរបស់ លោក ស៊ូ និងក្រុមបុរសដប់នាក់ នៅក្នុងទស្សនកិច្ចមកកាន់ប្រទេសកម្ពុជារបស់ពួកគេ រួមមាន អត្ថបទកាសែតពីសិង្ហបុរី ស្លាយ និងរូបថតដើម ផែនទីគូរដោយដៃ រូបភាព និងសៀវភៅកត់ត្រាផ្សេងៗផងដែរ។ សៀវភៅ *ដំណើរទស្សនកិច្ចនៅប្រទេសថៃ និងកម្ពុជា* (១៩៦៦) របស់លោក ម៉ាកូស៊ូ ក៏នឹងត្រូវ បានរួមបញ្ចូលជាបដិរូបមួយដែលជាការរិះគន់រចនាបថសិល្បៈស្រដៀង នឹងលោក ស៊ូ។ ផ្គួបផ្សំនឹងធនធានទាំងនេះ ក៏មានលោកសិល្បករ កូ ហ្វង ហាវ។ តាមរយៈវត្តមានជាសិល្បករស្នាក់ នៅនិវាសដ្ឋាននៅ ស-សបាសាក់ (ថ្ងៃទី ២៥ ខែកក្កដា ដល់ថ្ងៃទី ២៥ ខែសីហា ឆ្នាំ ២០១៦) លោក កូ នឹងរៀបចំការអនុវត្តន៍ និងការស្រាវជ្រាវ របស់គាត់ពីឆ្នាំ ១៩៨៩ មករួមមាន ការតាមដាន (ឡើងវិញ) និង «សម្លឹងជាលក្ខណៈតំបន់» នាថ្ងៃនេះ។ កិច្ចអន្តរាគមន៍ របស់គាត់រំលឹកយើងថា យើងអាចដឹងពីឯកសារ និងប្រវត្តិសាស្រ្ត តាមរយៈការបង្កើតរកចំនុចដែលវាទាក់ទង និងផ្ទុយគ្នា។

We are pleased to announce the exhibition and programs of *Singapore Art Archive Project @ SA SA BASSAC: Koh Nguang How and Shui Tit Sing* with curators Vera Mey and Mélanie Mermod, which positions Cambodia and the archive of Shui Tit Sing of the Ten Men Art Group as a focal point to unfold the multidirectionality of modern artistic movements in the region we have come to know as Southeast Asia.

Artist Koh Nguang How is one of the foremost chroniclers of contemporary art in Singapore, and initiated the *Singapore Art Archive Project (SAAP)* in 2005. The *SAAP* contains a treasury of photographs taken by Koh himself, video and audio documentation of performances and conversations as well as slides, brochures, catalogues, many relating to The Artists Village, a seminal contemporary art collective founded in 1988 by artist Tang Da Wu, of which Koh was a member. The wide range of Koh's materials collectively date between 1920s until now.

At SA SA BASSAC, Koh unfolds a cross-section of *SAAP* dating between 1963-1980, which focuses on the work of artist Shui Tit Sing (1914-1997). Shui was part of the Ten Men Art Group, a collective of males and females members who were primarily Chinese émigrés to Malaya and Singapore. Active between the years 1961 to 1970, they went in search of inspiration for a Southeast Asian aesthetic. The collectives' efforts and resulting pictorial styles were to merge largely with what was underway thirty years prior with the Nanyang School of Arts, and what would later become defined as "Nanyang Style." While the Ten Men Art Group was independent to the school, in principle they shared an East-East or self-Orientalizing view of a multicultural, southern tropical paradise to which they sought both inspiration from and belonging to.

The Ten Men Art Group travelled together, initiated exhibitions in Singapore, and held Sunday meetings to discuss and encourage artistic practice. Their travels took them to Indonesia, Borneo, Thailand, Cambodia and eventually India. Their 1970 trip to Sumatra was their last formal journey before forming as the Southeast Asian Art Association. The impact of the groups' field trips was visible through shifts in artistic practice, and they become especially known for their scenes of village life painted within a Beaux-Arts academic formation (via China) and through the context and influence of their relationship to location. Shui Tit Sing was especially impacted by his time in Cambodia and the temples within Angkor Archaeological Park, particularly the bas-reliefs of Bayon. He was inspired by ideas of synchronic time represented in the reliefs, and his monoscenic painting transformed into multi-register scenes. His sculpture, carved in teak wood, celebrated the common citizen as the modern regional hero.

The work on display at SA SA BASSAC is a combination of original and reproduced artworks from Shui Tit Sing's visit to Cambodia in 1963, and his subsequent inspiration through 1980. Alongside this will be ephemera selected from an extensive archive of Shui's and Ten Men's visit to Cambodia including newspaper articles from Singapore media outlets, original slides and photographs, hand drawn maps, drawings and notebooks. Marco Hsu's book *Jounal of Thailand and Cambodia Trip* (1966) will also feature as an example of an art critic documenting the artistic styles in close proximity to Shui. Complementing this material is the role of artist Koh Nguang How. Through his presence as SA SA BASSAC artist-in-residence (July 25-August 25, 2016), Koh will weave in his own research and practice dating from 1989 onwards, including actions of (re)tracing and "looking regionally" today. His interventions remind us that the archive is accessible to us through the present tense to provoke points of connection and contradiction.

# គម្រោងបណ្ណសារសិល្បៈសឹង្ហបុរីនៅស-សបាសាក់ ដោយ កូ ហ្ងួង ហាវ និង ស៊ូ ទិត្យ ស៊ីង

# Singapore Art Archive Project @ SA SA BASSAC
## Koh Nguang How and Shui Tit Sing

រៀបចំពិព័រណ៍ដោយ វេរ៉ា ម៉ៃ និង ម៉េឡានី មឺម៉ត
Curated by Vera Mey and Mélanie Mermod

31 July - 08 October, 2016



Koh Nguang How, *Bakong Ruins by Shui Tit Sing,1963*. Color photograph, 2014. Image courtesy Singapore Art Archive Project / Koh Nguang How

បណ្ណសារ *SAPP* ដ៏សំបូរបែបរបស់លោក កូ នៅស-សបាសាក់ និងមាតិកាផ្សេងៗរបស់វា អាចត្រូវបានគេពិនិត្យពីជ្រុង ជាច្រើនខុសៗគ្នា។ ទោះបីជាវាមានអាយុខុសគ្នា ៥០ ឆ្នាំក៏ដោយភាពខិតខំប្រឹងប្រែងរបស់លោក ស៊ូ ទិត្យ ស៊ីង និង កូ ហ្ងួង ហាវ មានភាពដូចគ្នា ព្រោះពួកគាត់ទាំងពីររូបខិតខំប្រឹងប្រែងរុករក និងកត់ត្រាប្រវត្តិសាស្ត្រដោយ ប្រើប្រាស់សិល្បៈ។ តាមគំនិតរបស់សិល្បករ *SAPP* ជាដំបូង ជាការសាកល្បងបង្ហាញពីតម្លៃខ្លឹមសារចម្បង ដែលនៅប្រកៀកការងាររបស់សិល្បករបំផុត នៅក្នុងទម្រង់ជាឯកសារ។ លើសពីនេះទៅទៀត ដោយការនាំមកនូវ បណ្ណសាររបស់លោក កូ និងលោក ស៊ូ ទិត្យ ស៊ីង មកប្រទេសកម្ពុជា អ្នករៀបចំនៅស-សបាសាក់ ជម្រុញឲ្យមាន ការវិភាគស៊ីជម្រៅមួយទៅលើគំនិតត្រង់ថា ប្រវត្តិសាស្ត្រសិល្បៈជាតិមានភាពដាច់ដោយឡែក និងឯកឯង ដូចគ្នាផងដែរនឹងការបង្កើតគំនិតក្នុងតំបន់ នៅពេលស្ថាប័ន និងគោលការណ៍ផ្សេងៗកំពុងត្រូវបានគេបង្កើតឡើង និងប្រជែងគ្នាក្នុងពេលតែមួយនៅប្រទេសសឹង្ហបូរី និងកម្ពុជា។ បណ្ណសារ SAAP/ស៊ូ ទិត្យ ស៊ីង ផ្តោតសំខាន់ លើមុខងាររបស់សឹង្ហបូរីជាអ្នករុករក ក៏ដូចជាអ្នកផ្តើមនូវតំបន់និយមតាម រយៈសិល្បៈ។ ធនធានទាំងនេះក៏បន្តឆ្លុះ បញ្ចាំងដល់ប្រវត្តិសាស្ត្រសិល្បៈ គំនិតសម្ហហភាព និងការផ្លាស់ប្តូរក្នុងប្រទេស និងទាក់ទងជាមួយប្រទេសកម្ពុជាផងដែរ។

The rich slice of Koh's *Singapore Art Archive Project at SA SA BASSAC*, as well as its entirety, can be considered from multiple vantage points. Although around 50 years apart – the efforts of Shui Tit Sing and Koh Nguang How mirror each other in a mutual effort to discover and document as a tool for rewriting history through art. *SAAP* was firstly from the artist's view an attempt to assert the value of primary materials closest to the artists' practices within the framework of an archive. Further, by inviting Koh and the Shui archive to Cambodia, the curators and SA SA BASSAC encourage an embedded criticality around notions of isolated, singular/national art histories as well as formations of regional ones at a time when institutions and canons in both Singapore and Cambodia are simultaneously being formed and contested. While the SAAP/Shui Tit Sing archive highlights the position of Singapore as both a seeker and instigator of regionalism through art, in turn, these materials extend art histories, notions of collectivity and exchange in and relating to Cambodia.